00773900

E138/1/7/2

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 01 / 02 / 2012
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

# អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿង ០០២ កាលបរិច្ឆេទ: ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២

ពី: Susan LAMB មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ: បច្ចុប្បន្នភាពពាក់ព័ន្ធនឹងសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងទៅអ្នកជំនាញវេជ្ជសាស្ត្រ ស្នើសុំព័ត៌មានថ្មីៗពាក់ព័ន្ធនឹងជនជាប់ចោទ អៀង ធីរិទ្ធ

បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ (ឯកសារ E138/1/7) អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់អ្នកជំនាញវេជ្ជសាស្ត្រដែលធ្លាប់វាយតម្លៃស្ថានភាពសុខភាពជនជាប់ចោទ អៀង ធីរិទ្ធ ឱ្យប្រគល់មកអង្គជំនុំជម្រះសាលាដំបូងនូវព័ត៌មានវេជ្ជសាស្ត្រពាក់ព័ន្ធដែលមានចាប់តាំងពីពេលជនជាប់ចោទ អៀង ធីរិទ្ធ បានទទួលការពិនិត្យលើកចុងក្រោយក្នុងខែកញ្ញា ឆ្នាំ ២០១១ ព្រមទាំងអនុសាសន៍សម្រាប់ការព្យាបាលបន្ថែម ដែលអាចដោះស្រាយបញ្ហាសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (ឯកសារ E138/1/7/1)។ បន្ទាប់ពីមានសំណើពីសំណាក់អ្នកជំនាញវេជ្ជសាស្ត្រ អង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ បានយល់ព្រមពន្យារពេលដល់អ្នកជំនាញក្នុងការដាក់របាយការណ៍របស់ខ្លួនរហូតដល់ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២។

Original EN: 00772278-00772278